**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៧៤៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ស្រុកស្រែអំបិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១២៩ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



៩

- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ស្រុកស្រែអំបិល** ដែលមានទីតាំងស្ថិតនៅភូមិនេសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ស្រុកស្រែអំបិល** មានទំហំ ១ ៨០០ ០០៤ម$^{២}$ (មួយលាន ប្រាំបីរយពាន់ បួនម៉ែត្រការ៉េ) ដូចមានប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីភ្ជាប់ជាឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ស្រុកស្រែអំបិល** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន សម្រាប់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ស្រុកស្រែអំបិល** នេះនឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ និងអភិបាលនៃគណៈអភិបាលខេត្តកោះកុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ស៊ុន ចាន់ថុល**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ក្រុមហ៊ុន ស្រែអំបិល ហ្វ្រី ត្រេដ ហ្សូន (ខេមបូឌា) ឯ.ក
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ប្លង់បន្ទាញទីតាំងដីគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុន ស្រែអំបិល ហ្វ្រី ត្រេដ ហ្សូន (ខេមបូឌា) ឯ.ក

ស្ថិតនៅភូមិទេនសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង

មាត្រដ្ឋាន : 1:9,000

តារាងនិយាមកានៃចំណុចព្រំដី

Projection UTM, Zone 48N, Datum WGS 84.

| Point_ID | Easting (m) | Northing (m) |
|---|---|---|
| 1 | 358033.840 | 1214191.740 |
| 2 | 358465.204 | 1214403.206 |
| 3 | 358609.500 | 1214473.245 |
| 4 | 358853.808 | 1214593.714 |
| 5 | 358840.131 | 1214699.832 |
| 6 | 358960.061 | 1214784.201 |
| 7 | 358900.573 | 1215135.227 |
| 8 | 358751.447 | 1215458.639 |
| 9 | 358612.399 | 1215760.192 |
| 10 | 358485.419 | 1216035.555 |
| 11 | 357927.797 | 1215789.612 |
| 12 | 357859.278 | 1215759.410 |
| 13 | 357288.984 | 1215507.858 |

ក្រឡាផ្ទៃដីស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស

របស់ក្រុមហ៊ុន ស្រែអំបិល ហ្វ្រី ត្រេដ ហ្សូន (ខេមបូឌា) ឯ.ក

| ល.រ | លេខក្បាលដី | លេខបណ្ណកម្មសិទ្ធិ | ក្រឡាផ្ទៃដី (ម៉ែត្រការ៉េ) |
|---|---|---|---|
| 1 | Cvii_0711 | ក.ក ០០៥៤៨២ | 1,000,006 |
| 2 | Cvii_0713 | ក.ក ០០៥៤៨៤ | 200,001 |
| 3 | Cvii_0714 | ក.ក ០០៥៤៨៥ | 200,002 |
| 4 | Cvii_0715 | ក.ក ០០៥៤៨៦ | 199,998 |
| 5 | Cvii_0716 | ក.ក ០០៥៤៨៧ | 199,997 |
| សរុប | | | 1,800,004 |

**សញ្ញាសំគាល់**

- • ចំណុចព្រំដី
- —— ព្រំដី
- ▨ ក្បាលដីស្នើសុំ

**ក្រឡាផ្ទៃដីសរុប : ១៨០,០០០៤ ហិកតា**

រៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង




យោងលិខិតលេខ : ១៣២៤ សជណ/អសអជ
ថ្ងៃ ៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៤
របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ថ្ងៃ ចន្ទ៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ស្រែអំបិល, ថ្ងៃទី៤៧ ខែ ឧសភា ឆ្នាំ ២០២៤
**ទាស់ទែង និងគូរដោយ**
ម៉ុក អ្នកខេន
លេខ: ០៤៧/២៤ ស.អ.ក.សជ
បានត្រួតពិនិត្យត្រឹមត្រូវ
គោរពជូនលោកប្រធានមន្ទីរមេត្តាពិនិត្យ-សម្រេច។
ថ្ងៃ ចន្ទ៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
ស្រែអំបិល, ថ្ងៃទី៤៧ ខែ ឧសភា ឆ្នាំ ២០២៤
**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីស្រុកស្រែអំបិល**
**ក្រុក សំអាន**

លេខ: ២៩៩
បានឃើញ និង ឯកភាព
ថ្ងៃ អង្គារ៍៦កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
កោះកុង, ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០២៤
**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកោះកុង**
**វិស្វករ សេរ៉ី វីរ៉ាវុធ**